ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៥-០១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០១០៤/០០៤ ស្តីពីការតែងតាំង ឯកឧត្តម **ឈរ ចាន់ណារ៉ាត** បច្ចុប្បន្នអគ្គាធិការរង ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងបរិស្ថាន ៧២

០៥-០១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០១០៤/០០៥ ស្តីពីការតែងតាំងឧត្តមសេនីយ៍ត្រី **យុន ទុន** ជាឧកញ៉ា ៧៣

០៨-០១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០១០៤/០០៦ ស្តីពីការតម្លើងឋានន្តរស័ក្តិ ជូនឯកឧត្តម **ហ៊ាន សាហ៊ីម** ពីវរមន្ត្រីថ្នាក់លេខ ៧ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៧៥

០៨-០១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០១០៤/០០៧ ស្តីពីការតែងតាំង ឯកឧត្តម **ទេព ម៉ុងឈី** ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលមានឋានៈស្មើរដ្ឋលេខាធិការ ជំនួស ឯកឧត្តម **ស៊ឹ ម៉ានិត** ៧៦


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


១៦-០១-២០០៤ -អនុក្រឹត្យ លេខ ០១ អនក្រ.បក ស្តីពីការទទួលស្គាល់ ការកែប្រែរចនាសម្ព័ន្ធ នៃវិទ្យាស្ថានឯកទេសនៃកម្ពុជា ទៅជា សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ៧៧

១២-០១-២០០៤ -អនុក្រឹត្យ លេខ ១១ អនក្រ.តត ស្តីពីការដកហូតមុខតំណែង និងតែងតាំងមន្ត្រីរាជការ ៨០

១២-០១-២០០៤ -អនុក្រឹត្យ លេខ ១២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨១

១២-០១-២០០៤ -អនុក្រឹត្យ លេខ ១៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨២

១២-០១-២០០៤ -អនុក្រឹត្យ លេខ ១៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៣

១៣-០១-២០០៤ -អនុក្រឹត្យ លេខ ១៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨៤

១៣-០១-២០០៤ -អនុក្រឹត្យ លេខ ១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥


## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៣-០១-២០០៤ -សារាចរណែនាំលេខ ០០១ សហវ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា ៨៧


### ២-ធនាគារជាតិ នៃ កម្ពុជា


១៤-០១-២០០៤ -ប្រកាសលេខ ធ៧.០៤.០០៦ ប្រក ស្តីពីការទូទាត់ភាគលាភជាមុន ៩៦

១៤-០១-២០០៤ -PRAKAS N.B7.04.006.Bror.Kor On PAYMENTS OF DIVIDENTS IN ADVANCE ៩៨


### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


០៨-០១-២០០៤ -ប្រកាសលេខ ០០២ ប្រក.កសក.ប ស្តីពីការតែងតាំងមន្ត្រីរាជការ ១០០

# ព្រះរាជក្រឹត្យ

នស/រកត/០១០៤/០០៤

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**ប្រកាសបង្គាប់**

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឈរ ទាំណាត បច្ចុប្បន្នអគ្គាធិការរង ជាអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងបរិស្ថាន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣៩ល.០៤.០១.០០៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤*

លេខៈ ០៩ ធ.ល

ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាវឌី តាន់**

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០១០៤/០០៥

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

តែងតាំង

ឧត្តមសេនីយ៍ត្រី ឃួន ខួង

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

ពរល.០៤.០១.០០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ លេខ: ០៨ ចព

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០១០៤/០០៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/២១១ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៣ ស្តីពីការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានតម្លើងឋានន្តរស័ក្តិ ជូនលោកឧត្តម ហ៊ាន សារ៉ុម ពីវរមន្ត្រី ថ្នាក់លេខ ៧ ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងស្មារតីនៃព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.-

[illegible] ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.-

ព្រះរាជក្រឹត្យនេះ មានអានុភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នស.០៤.០១.០០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មករា ឆ្នាំ២០០៤ លេខ: ០៦ ន.ស.

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៤/០០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ងោ ហុងលី** ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានឋានៈស្មើ **រដ្ឋលេខាធិការ** ជំនួសឯកឧត្តម **ស៊ុំ ម៉ានិត** ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខៈ ០៧ ធ.ល

ពរល.០៤-០១.០០៧

...ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០(

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាអ៊ី ចាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ ការកែប្រែរចនាសម្ព័ន្ធ នៃវិទ្យាស្ថានឯកទេសនៃកម្ពុជា ទៅជា សាកលវិទ្យាល័យឯកទេសនៃកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់វិទ្យាស្ថានឯកទេសនៃកម្ពុជា
- បានឃើញលិខិតលេខ ៧១១/០៣ វ.ឯ.ក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៣ របស់វិទ្យាស្ថានឯកទេសនៃកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

# ស ំ រេ ច

មាត្រា ១ : ទទួលស្គាល់ការកែប្រែចនាសម្ព័ន្ធ នៃវិទ្យាស្ថានឯកទេសនៃកម្ពុជា ទៅជា សាកលវិទ្យាល័យឯកទេសនៃកម្ពុជា "Cambodian University for Specialties" ហៅកាត់ជាភាសាខ្មែរ "**ស.ឯ.ក**" និង ហៅកាត់ជាភាសាអង់គ្លេស "C.U.S" ។

សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅ :

- អាគារលេខ ៤៣ ផ្លូវ ២៣១ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ
- អាគារលេខ ៥៨ ផ្លូវ ២៣០ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ
- អាគារលេខ ១៥ ផ្លូវ ១០៥ សង្កាត់បឹងព្រលឹត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ

និង សាខា ៣ កន្លែងស្ថិតនៅ :

- ផ្លូវលោកតាណើយ ភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប
- អតីតសណ្ឋាគាររតនៈ ត្រើយខាងកើតស្ទឹងសង្កែ ទល់មុខសាលាខេត្ត ខេត្តបាត់ដំបង
- អតីតផ្ទះសំណាក់ហាក់លី ភូមិ ៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

មាត្រា ២ : សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ :សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ។
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ ។
- ថ្នាក់ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ។

សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ត្រូវរៀបចំ កម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពី ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានមហាវិទ្យាល័យ :

១. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
២. មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
៣. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច
៤. មហាវិទ្យាល័យ វិស្វកម្ម
៥. មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ សំរាប់ពិនិត្យសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍ និង អនុម័តលើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : ក្នុងលក្ខខណ្ឌទទួលសិស្សអោយចូលរៀន សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ត្រូវគោរពតាមបទដ្ឋាន

របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពី ការជ្រើសរើស និស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រប់សាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន សាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាម សារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា អោយបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៨ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យឯកទេសនៃកម្ពុជា និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និង តាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយ សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញនិងអនុវត្តបាន តាមគោលការណ៍កំណត់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៩ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យឯកទេសនៃកម្ពុជា មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
- សាលាខេត្តសៀមរាប
- សាលាខេត្តបាត់ដំបង
- សាលាខេត្តកំពង់ចាម
  " ដើម្បីជ្រាប "
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដកហូតមុខតំណែង និងតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់
- តាមសំណើរបស់សហប្រធាន នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**សម្រេច**

**មាត្រា ១ :** ត្រូវបានដកតួនាទី និងភារកិច្ចលោក **ម៉ែន មុនីឃា** ពីប្រធានក្រុមគំរោងប័ណ្ណសារ និងពត៌មានវិទ្យា នៃអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **ជឹម ផេងស្រួយ** ជាប្រធានក្រុមគំរោងប័ណ្ណសារ និងពត៌មានវិទ្យា នៃអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលមានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ៣ :** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ . អនក្រ . [illegible]

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម:

១-លោកវរៈសេនីយ៍ទោ **ញៀម ផល្លា** អត្តលេខ ០៩៧៤ អនុប្រធាននាយកដ្ឋានពតិមានទូទៅ ។

២-លោកវរៈសេនីយ៍ទោ **អ៊ុយ សេរីកុល** អត្តលេខ ០៧៤១ អនុប្រធាននាយកដ្ឋានពតិមានទូទៅ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៣ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតសាលាភូមិន្ទចៅក្រម
- លិខិតលេខ០០១ ឧ.ក្រ.ធ ២០០៤ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៤ របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១** : តែងតាំងលោក **ទ៊ាន់ ផាន់** ជានាយកសិក្សានៃសាលាភូមិន្ទចៅក្រម មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយិកាសាលាភូមិន្ទចៅក្រម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *លេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ..១៤..អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតសាលាភូមិន្ទចៅក្រម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សំរេច

**មាត្រា ១** : តែងតាំងលោក **កើត សេកាណូ** ជាអគ្គលេខាធិការនៃសាលាភូមិន្ទចៅក្រម មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយិកាសាលាភូមិន្ទចៅក្រម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *លេខាធិការដ្ឋានផ្នែកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## សំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនតំណាងអង្គការផ្ទះទឹកដូង ចំនួន ០៥ រូប ដែលមានស្នាដៃល្អប្រសើរក្នុងការទំនាក់ទំនង និង សហការជាមួយអង្គការជាតិ-អន្តរជាតិ រកមូលនិធិ មកទ្រទ្រង់គំរោងសំរាប់ជួយដល់គ្រួសារអនាថា នៅក្នុងខេត្តបាត់ដំបង បានចំនួន ៥៧០.៨៨៣ ដុល្លារ ដូចមានរាយនាមខាងក្រោមនេះ :-

**ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

- លោកស្រី **សៀវ ឡាយហួយ** នាយិកា អង្គការផ្ទះទឹកដូង

**ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

- លោកស្រី **សារី វ៉េត** នាយិការង អង្គការផ្ទះទឹកដូង

**គ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

១-លោកស្រី **ទ្រាហ្ម គីមនេង** អ្នកគ្រប់គ្រងផ្នែកអប់រំ និង ហិរញ្ញវត្ថុ
២-លោកស្រី **សូ ស៊ិនណារី** អ្នកគ្រប់គ្រងផ្នែកសុខភាព និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ
៣-លោកស្រី **លឹម សុវណ្ណ** ជំនួយការរដ្ឋបាល

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៨ រូប ដែលបានឧបត្ថម្ភ ជាថវិកា ចូលរួមជំរុញការងារ ក្នុងអង្គការផ្ទះទឹកដូង និង ជួយកសាងសមិទ្ធផលនានា ជាប្រយោជន៍ដល់ គ្រួសារអនាថា នៅក្នុងខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-លោក ***Jose ' Luis Guirao*** អ្នកបង្កើតអង្គការផ្ទះទឹកដូង និង ជួយឧបត្ថម្ភកម្មវិធី ថវិកា ចំនួន ៥២.៣០០ **USD**

២-លោក ***Rob Van Berkel*** តំណាងម្ចាស់មូលនិធិផ្ទះទឹកដូង ហូឡង់ ថវិកា ចំនួន ៥១.៦០០ **USD**

៣-លោក ***Michiel Alting Von Geusau*** តំណាងម្ចាស់មូលនិធិ ***Duch Soldier Holland*** ថវិកា ចំនួន ២៦.៤៣០ **USD**

៤-លោកស្រី ***Maria Jose '*** តំណាងម្ចាស់មូលនិធិផ្ទះទឹកដូង អេស្ប៉ាញ ថវិកា ចំនួន ២៦.៣០០ **USD**

៥-លោកស្រី ***Aya Mizusawa*** តំណាងម្ចាស់មូលនិធិស្ថានទូតជប៉ុន ថវិកា ចំនួន ១៩.៧៤៥ **USD**

៦-លោក ***Nicole Schenda*** តំណាងម្ចាស់មូលនិធិ ***Women World Day of Prayer*** អាល្លឺម៉ង់ ថវិកា ចំនួន ១៨.៥០០ **USD**

៧-លោក ***Pietro Parrino*** តំណាងម្ចាស់មូលនិធិ ***CIAI Italy*** ថវិកា ចំនួន ១០.៥០០ **USD**

**ខ_ មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក ***Rodney Hacsielt*** តំណាងម្ចាស់មូលនិធិ ***UNICEF*** ថវិកា ចំនួន ៨.៣០០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០១ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៤

# សារាចរណែនាំ

## ស្តីពី

## ការកែលំអនីតិវិធីអនុវត្តថវិកា

- យោងអនុក្រឹត្យលេខ ៨១ អនក្រ.កប ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង-ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការ សាធារណៈរដ្ឋបាល

- យោងអនុក្រឹត្យលេខ ៨២ អនក្រ.កប ចុះថ្ងៃទី១៦ ខែ វិច្ឆិកាឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- យោងប្រកាសលេខ ៦១៩ សហវ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ

- អនុលោមតាមស្មារតីនៃអង្គប្រជុំ របស់គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ នាថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៣

ដើម្បីធានាការអនុវត្តន៍ថវិការដ្ឋប្រកបដោយប្រសិទ្ធភាពផ្សារភ្ជាប់ជាមួយការគ្រប់គ្រងសាច់ប្រាក់ស្របតាមគោលការណ៍អភិបាលកិច្ចល្អក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីវិធានការមួយចំនួនក្នុងការអនុវត្តន៍នីតិវិធីអនុវត្តថវិកា ដូចតទៅ:

### ១. អំពីការគ្រប់គ្រងឥណទានថវិកា

#### ក-វិធានការពង្រឹងវិន័យថវិកា

កិច្ចការនេះវាជាភារៈទទួលខុសត្រូវផ្ទាល់របស់ក្រសួង-ស្ថាប័ននានា និងមន្ទីរជំនាញគ្រប់ខេត្ត-ក្រុង តែក៏ស្ថិតនៅក្រោមអំណាចនៃការត្រួតពិនិត្យនិងគ្រប់គ្រងផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ ។ ដូចនេះ ដើម្បីបង្កើនការទទួលខុសត្រូវក្នុងកិច្ចប្រតិបត្តិការចំណូល-ចំណាយក៏ដូចជាក្នុងសកម្មភាពគ្រប់គ្រងថវិកាជាតិ គ្រប់ក្រសួង-ស្ថាប័ននានារួមទាំងមន្ទីរជំនាញគ្រប់ខេត្ត-ក្រុង និង អង្គភាពជំនាញ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថិតក្នុងស្ថានភាពលំបាកចំពោះមុខត្រូវមានវិធានការពង្រឹងវិន័យថវិកាឱ្យកាន់តែប្រសើរតាមបរិបថចំណាយហិរញ្ញវត្ថុសាធារណៈនិងតាមភារកិច្ចរៀងៗខ្លួន ដូចតទៅ :

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798

**_-វិធីចំណូល_ :**

+ ត្រូវបង់ចូលថវិការដ្ឋទាំងអស់ មិនត្រូវផាត់ទាត់ជាមួយចំណាយឡើយ ។

+ ត្រូវធ្វើចលនាប្រមូលផ្តុំប្រាក់ចំណូលគ្រប់ប្រភេទពីគ្រប់ប្រភព ហើយកត់ត្រាចុះបញ្ជី និងបង់ចូលថវិការដ្ឋ ឱ្យបានទៀងទាត់តាមច្បាប់និងបទបញ្ញាជាធរមាន ។

+ ត្រូវតាមដានជាប្រចាំនូវសេក្តីប័ត្របង់ចំណូលជាមួយបញ្ជីសំរង់ចំណូល ហើយផ្ទៀងផ្ទាត់រៀងរាល់ខែ ជាមួយសៀវភៅតល់បញ្ជីបង្កាន់ដៃ ។

+ ត្រូវតឹងទារបំណុលពីអ្នកជំពាក់បំណុលរដ្ឋ សំដៅបញ្ចៀសឱ្យបាននូវការខាតបង់ចំណូលថវិកាជាតិ ។

+ ត្រូវលុបបំបាត់ឱ្យអស់ និងជាបន្ទាន់នូវទង្វើរក្សាប្រាក់ចំណូលសំរាប់ចំណាយ ។ សាច់ប្រាក់រាចដិកល់ទុកបានក្នុងបេឡាមិនត្រូវឱ្យលើសពីចំនួនបានកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ០១៤ ប្រក. សហវ.រជ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៧ នោះឡើយ ។ ចំនួនសាច់ប្រាក់ដែលភ្នាក់ងារ ឬ អង្គភាពនិមួយៗអាចរក្សាទុកក្នុងបេឡារបស់ខ្លួនត្រូវបានកំណត់ត្រឹមចំនួន :

- ចំពោះ**រដ្ឋទេយ្យករចំណូល**មិនលើសពីចំនួន **២.០០០.០០០រៀល** ( ពីរលានរៀល)
- ចំពោះ**គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ( នាយកដ្ឋានពន្ធដារនិងទីចាត់ការគយនិងរដ្ឋាករ)** :
  - នៅរាជធានីភ្នំពេញមិនឱ្យលើសពី **៥.០០០.០០០រៀល** ( ប្រាំលានរៀល)
  - នៅតាមបណ្តាខេត្ត-ក្រុងមិនឱ្យលើសពី **២.០០០.០០០រៀល** ( ពីរលានរៀល)

_-វិធីចំណាយ_ :

+ ត្រូវចំណាយក្នុងក្របខ័ណ្ឌឥណទានថវិកាដែល ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំអនុញ្ញាត ។

+ ត្រូវប្រតិបត្តិឱ្យបានហ្មត់ចត់និងត្រឹមត្រូវតាមនីតិវិធី និងតាមរបបថ្នៃការត្រួតពិនិត្យហិរញ្ញវត្ថុ ដូចមានខ្លឹមសារចែងក្នុងអនុក្រឹត្យ លេខ ៨១ អនក្រ.តប ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

+ ត្រូវធ្វើឱ្យបានត្រឹមត្រូវនិងមានតម្លាភាព នៅក្នុងការអនុវត្តន៍បទបញ្ញានិងនីតិវិធីលទ្ធកម្មសាធារណៈ ។

+ ត្រូវខិតខំសន្សំសំចៃនិងត្បិតត្បៀតលើចំណាយថវិការដ្ឋ ។

+ ត្រូវលុបបំបាត់ជាបន្ទាន់នូវទង្វើខុសច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដូចជា :

- ទម្លាប់យកចំណូលទៅចំណាយមុន រួចចាំស្នើសុំថវិកាមកបំពេញវិញ
- ទម្លាប់ខ្ចីសំភារៈបរិក្ខារពីអតិថិជនប្រើប្រាស់មុន ដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មិនយកចិត្តទុកដាក់ក្នុងការប្រមូលឯកសារទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទានពិសេសទូទាត់ថវិកា បុរេប្រទានមិនទាន់តាមកាលកំណត់
- ចំណាយក្រៅរង្វង់ថវិកាអនុម័ត តាមនីតិវិធីចំណូលព្រម-ចំណាយព្រម ។

+ ត្រូវបង្កើនការទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណាយសាធារណៈ សំដៅលេចឱ្យឃើញនូវ :

- លទ្ធផលល្អប្រសើរនិងមានប្រសិទ្ធភាពខ្ពស់
- តម្លាភាពនិងគណនេយ្យភាព ។

+ ត្រូវតាមដានការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ សំខាន់គឺត្រូវអនុវត្តឱ្យបានល្អតាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសដោយបែងចែកលំអិតតាមខែ និងដោយ**ផ្អែកលើសមិទ្ធិផលជាក់ស្តែងនៃការប្រមូលចំណូល** ។

+ ត្រូវខិតខំរឹតបន្តឹងវិធីគ្រប់គ្រងចំណាយថវិកា ដោយមិនអនុញ្ញាតឱ្យមានការអនុវត្តន៍ចំណាយណាមួយរំលោភលើគោលការណ៍នៃបរិបថចំណាយឡើយ ។

+ ត្រូវប្រមូលផ្តុំពតិមាននិងការបូកសរុបលើការសន្យាចំណាយ និងការចេញអាណត្តិបើករាល់ខែ ដោយធានាមិនឱ្យមានអាណត្តិកកស្ទះនៅរតនាគារជាតិ លើសពីមួយភាគដប់ពីរនៃចំណូលចរន្តប្រចាំឆ្នាំឡើយ ។

+ ត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយថវិការវាងគណនេយ្យរដ្ឋបាលរបស់ក្រសួងចំណាយជាមួយនឹងគណនេយ្យករចំណូល-ចំណាយរបស់រតនាគារជាតិ ។

ខ-**អំពីទិដ្ឋាការនៃការសន្យាចំណាយ**

- ដើម្បីឱ្យការអនុវត្តន៍នីតិវិធីលទ្ធកម្មសាធារណៈប្រព្រឹត្តទៅមានភាពងាយស្រួល ការផ្តល់ធានាចំណាយថវិកាសំរាប់ឆមាសទី១យ៉ាងខ្ពស់បំផុតត្រឹម ៦០% ។

- នៅដើមខែមិថុនានៃឆ្នាំថវិកានីមួយៗ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យសារឡើងវិញនូវសភាពការណ៍អនុវត្តចំណូល-ចំណាយថវិកា ដោយធ្វើការវាយតម្លៃនូវសភាពការណ៍អនុវត្តថវិកាឆមាសទី១ និងធ្វើការប៉ាន់ស្មានអនុវត្តឆមាសទី២ ។ ក្នុងករណីសភាពការណ៍អនុវត្តថវិកាមានការប្រែប្រួលច្រើនខុសពីការគ្រោងទុក ត្រូវធ្វើការសម្របសម្រួលការអនុវត្តន៍ថវិកាឆមាសទី២ ដោយមានវិធានការបង្កើនចំណូលនិងកាត់បន្ថយចំណាយថវិកា ឬ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុកែតំរូវ ។

- ការធានាចំណាយសំរាប់ឆមាសទី២ ត្រូវធ្វើឡើង តាមការប៉ាន់ស្មានអនុវត្ត ៦ខែចុងឆ្នាំ ឬតាមការប្រែប្រួលឥណទានថវិកាកែតំរូវ ។

គ-**អំពីទិដ្ឋាការលើអាណត្តិបើកប្រាក់**

ដំណាក់កាលនៃការចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ គឺធ្វើក្រោយពេលដែលទំនិញទាំងឡាយត្រូវបានប្រគល់-ទទួល ឬការងារ ក៏ដូចជាសេវាទាំងឡាយត្រូវបានសម្រេចរួចហើយ ។ អាណាប័កត្រូវធ្វើការចាត់ចែងទូទាត់ជំរះចំណាយតាមចំនួនទឹកប្រាក់ពិតប្រាកដ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ជាក់លាក់និងត្រឹមត្រូវ ប៉ុន្តែ ទោះយ៉ាងនេះក្តី រាល់ការរៀបចំ អាណត្តិកិច្ចអាណាប័កត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃសំណុំលិខិតយុត្តិការនិងកិច្ចសន្យា និងកម្មវិធីចំណូល-ចំណាយសាច់ប្រាក់ប្រចាំខែ ដូចតទៅ :

- ត្រូវភ្ជាប់មកជាមួយនូវលិខិតយុត្តិការពាក់ព័ន្ធទាំងឡាយ សំរាប់ជាសំអាងក្នុងការទូទាត់ និងផ្តល់ចំណាយ
- ត្រូវផ្ទៀងផ្ទាត់និងពិនិត្យឱ្យបានល្អិតល្អន់អំពីសុពលភាពនៃសំណុំលិខិត ។
- ត្រូវបញ្ចៀសនូវ :
  - ការចុះកិច្ចសន្យាផ្គត់ផ្គង់ដែលតម្រូវឱ្យធ្វើការទូទាត់ទាំងស្រុងតែម្តង ដែលមិនសមស្របទៅនឹង

កម្មវិធីសាច់ប្រាក់ និងលទ្ធភាពថវិកា ។

- ការបោះផ្សាយអាណត្តិបើកប្រាក់**ដោយតំហុក** លើសពីកម្មវិធីសាច់ប្រាក់ដែលបានគ្រោងទុក ។
- ការបង្អាកឯកសារត្រូវទូទាត់ឱ្យនៅ**ពួនគរហូតដល់ចុងឆ្នាំ**ទើបរៀបចំធ្វើអាណត្តិកិច្ច ជាហេតុធ្វើឱ្យប៉ះពាល់ដល់កម្មវិធីសាច់ប្រាក់ចុងឆ្នាំ ។

- ត្រូវធ្វើត្រឡប់វិញឬព្យួរទុកការទូទាត់នូវអាណត្តិបើកប្រាក់ទាំងឡាយ ដែលមានមូលហេតុដូចខាងក្រោមៈ
  - ភាពមិនទំនេរនៃឥណទាន
  - ពុំមានទិដ្ឋាការសន្យាចំណាយ
  - ពុំមានលិខិតយុត្តិការបញ្ជាក់ពីសេវាបានធ្វើហើយ ឬមិនត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ
- រាល់ការជំទាស់ ត្រូវមានការសម្រេចនិងជូនដំណឹងតាមនីតិវិធីរដ្ឋបាល ។

### ឃ-អំពីចលនាឥណទានថវិកា

ការធ្វើចលនាឥណទានពីជំពូកមួយទៅជំពូកមួយ ទោះបីត្រូវបានអនុញ្ញាតក៏ដោយ ក៏ការបង្វែរឥណទានច្រើន ហួសហេតុ និងបញ្ជាក់អោយឃើញថាការរៀបចំគំរោងថវិកាមិនបានស្របទៅតាមតម្រូវការចំណាយជាក់ស្តែងរបស់ខ្លួន ។ ដូច្នេះ ក្នុងការអនុវត្តន៍ថវិកាពីដើមត្រីមាសទី១ រហូតដល់ចុងត្រីមាសទី៣ នៃឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិន អនុញ្ញាតឱ្យក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង ធ្វើចលនាឥណទានថវិកាដោយបង្វែរពីជំពូកមួយទៅជំពូកមួយ នៅក្នុងក្របខ័ណ្ឌប្រភេទអន្តរាគមន៍តែមួយដូចគ្នាបានទេ ក្នុងនោះ ហាមធ្វើចលនាឥណទាន ដោយធ្វើការ បង្វែរ ឥណទានពីជំពូកមួយដែលមានចរិតលក្ខណៈជាឥណទាន " វាយតំលៃបាន" ទៅជំពូកមួយទៀតដែលមានចរិតលក្ខណៈ ជាឥណទាន "គំហិត" ដូចជា : ការបង្វែរឥណទានពី ជំពូក១០ (បៀវត្ស និង ប្រាក់បំណាច់) ទៅជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និង ការជួសជុលតូច) ទោះបី ជំពូកទាំងពីរនេះស្ថិតនៅក្នុងក្របខ័ណ្ឌប្រភេទ មធ្យោបាយ សេវា តែមួយដូចគ្នាក៏ដោយ តែជំពូកទាំងពីរនេះជាឥណទាន មានចរិតលក្ខណៈផ្ទុយគ្នា ។ នៅក្នុងការអនុវត្តន៍ ថវិកា បើមានការខ្វះខាតឥណទានជំពូក ១០ ឬជំពូក ៣១ ដែលមានចរិតលក្ខណៈជាឥណទាន " វាយតំលៃបាន" ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង ត្រូវលើកសំណើសុំនិយ័តភាពពីជំពូកដទៃទៀត មកបំពេញបន្ថែម តាមការចាំបាច់ ។

## ២. អំពីការគ្រប់គ្រងប្រាក់បុរេប្រទាន

កន្លងមក នៅក្នុងបរិបទចំណោយហិរញ្ញវត្ថុសាធារណៈ មានការអនុវត្តន៍បន្ថែមនូវយន្តការបើកផ្តល់ចំណាយតាមរូបភាព រជ្ជទេយ្យបុរេប្រទានផង និងបុរេប្រទានផង ដោយផ្អែកតាមសំណូមពរដោយថាហេតុរបស់បណ្តាក្រសួងនិងស្ថាប័ន ។ ប្រការនេះ បានធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាចរន្ត សំខាន់គឺប៉ះពាល់ដល់កម្មវិធីចំណូល-ចំណាយសាច់ប្រាក់ប្រចាំខែ ដែលជាហេតុបណ្តាលឱ្យកើតមានបញ្ហាដកសាច់ប្រាក់បុរេប្រទាន ទៅប្រើប្រាស់មិនបាននៅក្នុងពេលបច្ចុប្បន្ននេះ ។ ដូចនេះ គ្រប់ក្រសួង-ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវតែកាត់បន្ថយនិងបញ្ចៀសឱ្យបាននូវ ទម្លាប់ពង្រីកយន្តការប្រើប្រាស់ថវិកាបុរេប្រទាននេះ ។

ដើម្បីបន្ថយបាននូវបាតុភាពមិនប្រក្រតីនេះ គ្រប់ក្រសួង-ស្ថាប័ន និងគ្រប់ខេត្ត-ក្រុងត្រូវកែលំអនីតិវិធីចំណាយតាមរូបភាពបុរេប្រទាននេះ ដូចតទៅ :

១- ត្រូវអនុវត្តនីតិវិធីចំណាយដូចធម្មតាដើម្បីបញ្ចៀសចំណាយតាមបែបបុរេប្រទាន ។

២- ត្រូវលើកសំណើសុំចំណាយថវិកាបុរេប្រទានចំពោះតែចំណាយទាំងឡាយណាដែលកើតឡើងក្នុងករណីចាំបាច់ និងបន្ទាន់បំផុតប៉ុណ្ណោះ ។

៣- ត្រូវលើកកម្មវិធីស្នើសុំចំណាយថវិកាបុរេប្រទានតាមកាលបរិច្ឆេទជាក់លាក់ ដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រៀមដាក់បញ្ចូលក្នុងកម្មវិធីសកម្មភាពសាច់ប្រាក់ជាមុន ។

៤- ត្រូវប្រមែប្រមូលសក្ខីប័ត្រ និងយកចិត្តទុកដាក់ធ្វើរភាវូបនីយកម្ម ដើម្បីទូទាត់ថវិកាបុរេប្រទានឱ្យបានតាមកាលបរិច្ឆេទកំណត់ដូចតទៅ :

**ក-ចំពោះប្រាក់បុរេប្រទានមានលក្ខណៈចាំបាច់ និង បន្ទាន់**

- នៅចុងត្រីមាសទីមួយនៃឆ្នាំថវិកា ត្រូវជំរះបញ្ជីឱ្យបាននូវរាល់ជាវភាវូបនីយកម្មបោះផ្សាយ និងត្រូវបានរតនាគារជាតិ និងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណលុបចេញពីបញ្ជីបុរេប្រទានយ៉ាងតិចចំនួន **២ ភាគ ៣** នៃប្រាក់បុរេប្រទានទាំងអស់ដែលដល់ថ្ងៃកំណត់ឱ្យជំរះបញ្ជីទូទាត់ក្នុងរង្វង់ត្រីមាសទី១ ។ ក្នុងករណីក្រសួង-ស្ថាប័នណាដែលមិនជំរះបញ្ជីជាស្ថាពរនូវចំនួន ២ភាគ៣ ក្នុងដំណាក់កាលត្រីមាសទី១នេះទេ ក្រសួង-ស្ថាប័ននោះមិនត្រូវបានអនុញ្ញាតឱ្យបន្តធ្វើសំណើប្រាក់បុរេប្រទាន ជាយថាហេតុនៅដំណាក់កាលត្រីមាសទី២ទៀតទេ ។
- ត្រីមាសទី២ ត្រូវជំរះបញ្ជី ១ ភាគ ៣ ដែលនៅសល់ពីត្រីមាសទី១ និង ២ភាគ៣ នៃត្រីមាសទី២ ។
- ត្រីមាសទី ៣ ក៏ត្រូវធ្វើកិច្ចជំរះបញ្ជីតាមគោលការណ៍និងនីតិវិធីដូចបានកំណត់នៅត្រីមាសទី២ ដែរ ។ ក្នុងករណីក្រសួង-ស្ថាប័នណា ដែលមិនធ្វើកិច្ចជំរះបញ្ជីជាស្ថាពរនូវចំនួន ១ ភាគ៣ ដែលនៅសល់ពីត្រីមាសមុន និង ២ ភាគ ៣ នៃត្រីមាសបន្ទាប់ ក្រសួង-ស្ថាប័ន នោះមិនត្រូវបានអនុញ្ញាតឱ្យបន្តធ្វើសំណើប្រាក់បុរេប្រទានជាយថាហេតុនៅដំណាក់កាលត្រីមាសបន្ទាប់ ទៀតទេ ។

- ចំពោះត្រីមាសទី៤ ត្រូវជំរះបញ្ជីជាស្ថាពរនូវចំនួន ១ភាគ៣ ដែលនៅសល់ ពីត្រីមាសទី៣ ហើយសំណើប្រាក់បុរេប្រទានជាយថាហេតុសំរាប់ត្រីមាសទី៤នេះ **អាចធ្វើទៅបានលុះត្រាតែមានឥណទាននៅសល់ទំនេរ** ក្នុងថវិកាជំពូកទាន់ ឬថវិកាកែតំរូវ ។
- ជាទូទៅ មិនត្រូវមានប្រាក់បុរេប្រទានដែលមិនបានជំរះបញ្ជីទាំងស្រុង គ្រប់ នាដំណាច់ឆ្នាំនីមួយៗឡើយ ។ ដូចនេះប្រាក់បុរេប្រទាន ត្រូវតែបានគ្រប់គ្រងយ៉ាងហ្មត់ចត់ និងត្រូវបានជំរះបញ្ជីជាស្ថាពរ ជាបណ្តើរៗ ក្នុងខែនីមួយៗ និងបានទាំងស្រុងក្នុងអំឡុងពេលអនុវត្តឆ្នាំថវិកានោះតែម្តង ។ ធ្វើរបៀបនេះ ទើបបញ្ចៀសបាននូវការពន្យារប្រាក់បុរេប្រទាន ដែលកន្លងមកតែងធ្វើការជំរះបញ្ជីនាចុងឆ្នាំតែប៉ុណ្ណោះ ឬមិនព្រមជំរះបញ្ជី ដោយទុកចោលពីមួយឆ្នាំ ទៅ មួយឆ្នាំ ។
- ប្រសិនបើមានប្រាក់បុរេប្រទានរបស់ក្រសួង-ស្ថាប័នណាមួយនៅតែពុំមិនបានជំរះបញ្ជី ហើយស្ថិតនៅក្នុងបញ្ជីគណនេយ្យរបស់រតនាគារជាតិ ឬ អង្គភាពគ្រប់គ្រងរូបិយវត្ថុ ក្នុងកិច្ចអនុវត្តន៍ថវិកាឆ្នាំ ២០០៣ និងឆ្នាំខាងមុខជាបន្តបន្ទាប់

ក្រសួង-ស្ថាប័ននោះ នឹងមិនត្រូវបានជំរុញលើកទឹកចិត្តអោយបន្តអនុវត្តយន្តការប្រាក់បុរេប្រទាន នៅឆ្នាំបន្ទាប់ឡើយ ។

**ខ-ចំពោះប្រាក់បុរេប្រទានមានលក្ខណៈជាប្រាក់រំដោះ ឬ ក្នុងល័ក្ខខ័ណ្ឌដែលមានចែងអោយមានបញ្ញាបត្រ**

ផ្អែកតាមកិច្ចសន្យាជាធរមាន ប្រាក់បុរេប្រទានប្រភេទនេះអាចប្រគល់អោយអ្នកផ្គត់ផ្គង់បាន តែមិនអោយលើស ពីចំនួន ២៥% នៃតំលៃកិច្ចសន្យាឡើយ ។ ប្រាក់បុរេប្រទាននេះនឹងត្រូវបានជំរះបញ្ជីជាបណ្តើរៗ តាមកិច្ចសន្យាដែលបានចែង ។

## ៣. អំពីការគ្រប់គ្រងកម្មវិធីចំណូល-ចំណាយ

យោងតាមសារាចរលេខ ០០១ សហវ.ថវ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ២០០២ ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស នៅតែជាធរមាន ។ ក៏ប៉ុន្តែ ការរៀបចំកម្មវិធីចំណូល-ចំណាយនេះ ត្រូវធ្វើការកែលំអ ដូចខាងក្រោម:

- ត្រូវគិតបញ្ចូលតំរូវការប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន អាណត្តិបើកប្រាក់ដកលុយទុកនៅរតនាគារជាតិ និង អាណត្តិបើកប្រាក់កកស្ទះរបស់ក្រសួង-ស្ថាប័ននានាទៅក្នុងកម្មវិធីចំណូល-ចំណាយថវិកា ប្រចាំខែ ត្រីមាស ចាប់ពីដើម ដំបូងនៃការអនុវត្តថវិកាឆ្នាំ ២០០៤ តទៅ ។

- ត្រូវលុបបំបាត់ការធ្វើកម្មវិធីបន្ថែមចំណាយ ដើម្បីបោះផ្សាយអាណត្តិបន្ថែមជាស្វ័យប្រវត្តិ នៅក្នុងកម្មវិធី ចំណូល-ចំណាយប្រចាំត្រីមាស ។ អាចបន្ថែមកម្មវិធីចំណាយជូនបានតែក្នុងករណីមានសំណើកម្មវិធីក្រោយពីធ្វើការផ្ទៀងផ្ទាត់ រវាងកម្មវិធីនិងការអនុវត្តន៍ជាក់ស្តែង ។

- ត្រូវធ្វើការកែតំរូវ មុខតំណែងនូវតួលេខព្យាករណ៍ចំណូលប្រចាំខែ ជាមួយនឹងតួលេខចំណូលដែលបាន ប្រមូល ជាក់ស្តែងដោយផ្អែកតាមតារាងប្រតិបត្តិការបរិញ្ញវត្ថុសាធារណៈ (TOFE) ក្នុងខែកន្លងទៅរួចហើយពិនិត្យវាយតំលៃចំណាយ ក្នុងស្រុកដែលត្រូវមានចំណាយចរន្ត ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស និងចំណាយរំលស់ បំណុលជាក់ស្តែង ប្រៀបធៀបជាមួយចំណូលក្នុងស្រុកជាក់ស្តែងក្នុងខែនោះ ។ ក៏ប៉ុន្តែ ការប្រៀបធៀបរវាង ចំណូល-ចំណាយតែប៉ុណ្ណេះមិនទាន់ សន្និដ្ឋានបានថាសាច់ប្រាក់ទំនេរនៅរតនាគារជាតិបានទេ ពីព្រោះការគ្រប់គ្រង សាច់ប្រាក់បច្ចុប្បន្ន ត្រូវយកចំណូលជា សាច់ ប្រាក់ក្នុងខែ សំរាប់បើកផ្តល់បុរេប្រទានផង សំរាប់បើកផ្តល់ (មូទាត់) បំណុលសាច់ប្រាក់ដែលពន្យារ នាឆ្នាំមុនៗផង ឬអាណត្តិ បើកប្រាក់ PAP ឆ្នាំកន្លងមកផង ។ល។ ម្យ៉ាងវិញទៀត ក៏មានចំណូលខ្លះគត់ត្រាកើនឡើងក្នុងខែ តែយកទៅកាត់កងជាមួយ បំណុលក្រុមហ៊ុនឆ្នាំមុន ។ ដូចនេះ ផ្នែកចំណាយមិនត្រូវបានកត់ត្រាម្តងទៀតក្នុងខែនោះបានឡើយ ។ ក្នុងករណីនេះនឹងនាំឱ្យ ឃើញថា ចំណូលក្នុងខែកើន ខ្ពស់ តែចំណាយក្នុងខែវិញនៅទាប ។

- បង្កើនស្រួលការធ្វើកម្មវិធីចំណាយប្រចាំខែ ត្រីមាស ឱ្យស្មើនឹង ចំនួនព្យាករណ៍ចំណូលនៃខែ ត្រីមាសនោះពិត្រូវ ធ្វើឱ្យមានចំលាស់ ៧ ទៅ ១០% នៃការព្យាករណ៍ចំណូលខែ ត្រីមាស ។

- រាល់កម្មវិធីចំណូល-ចំណាយ ត្រូវបានដាក់ជូន គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ពិនិត្យនិងអនុម័ត មុននឹងដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរេច ។

## ៤. អំពីការគ្រប់គ្រងបំណុលសាច់ប្រាក់ក្នុងអាណត្តិមិនទាន់ទូទាត់

ដើម្បីបន្ថយស្តុកនៃបំណុលសាច់ប្រាក់ជាទូទៅ និង ដោយអនុវត្តនូវសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៤ តទៅ រតនាគារជាតិនិងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណត្រូវរៀបចំសន្សំ សាច់ប្រាក់ពីចំណូលថវិការដ្ឋតាមឥណទានដែលបានគ្រោងក្នុងជំពូក៩៣ ដែលបានកំណត់ក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៤ សំដៅកាត់បន្ថយស្តុកនៃបំណុលសាច់ប្រាក់ឱ្យបានជាបណ្តើរៗពីក្នុងអាណត្តិមិនទាន់ទូទាត់ រហូត បំណុលប្រភេទនេះបញ្ចប់ជាស្ថាពរ ។ ទន្ទឹមនេះដែរ មិនអនុញ្ញាតឱ្យធ្វើនិយ័តភាពពីជំពូក៩៣នេះ ទៅជំពូកផ្សេងទៀតទេ ។

## ៥. <u>វិធីការគ្រប់គ្រងបំណុលសារពើពន្ធនិងបំណុលពុំមែនសារពើពន្ធ</u>

ចំណូលថវិកាត្រូវតែពិតខំគៀងគរប្រមូលផ្តុំនិងដាក់បញ្ចូលក្នុងរតនាគារជាតិទាំងអស់ ។ និយាយដោយឡែក ចំណូលពីបំណុលពន្ធដារ បំណុលពន្ធគយនិងរដ្ឋាករ និងបំណុលពុំមែនសារពើពន្ធដែលជំពាក់រដ្ឋផ្សេងៗទៀត ដូចជាបំណុលពីការលក់ និងជួល ទ្រព្យសម្បត្តិរដ្ឋ... ។ល។ ត្រូវមានវិធានការពឹងទារដូចតទៅ :

- មិនអនុញ្ញាតឱ្យ**បោះបង់ ឬលុបចោល**នូវ បំណុលពន្ធ ឬបំណុលជំពាក់រដ្ឋណាមួយខុសពីបទប្បញ្ញត្តិឡើយ មានជាអាទិ៍ :

  - បំណុលពន្ធដារ
  - បំណុលពន្ធគយនិងរដ្ឋាករ
  - បំណុលពុំមែនសារពើពន្ធ ដូចជា បំណុលពីការលក់ ជួល ផ្ទេរភោគចក្រ សហគ្រាស អចលនទ្រព្យផ្សេងៗរបស់ក្រសួង ស្ថាប័ន បំណុលពីទេសចរណ៍ បំណុលពីទីផ្សារការទិញលិខិតឆ្លងដែន បំណុលប្រៃសណីយ៍និង ទូរគមនាគមន៍ បំណុលពីវិស័យអាកាសចរ និងពត៌មាន... ។ល។

- នាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ត្រូវផ្តល់**បញ្ជីបំណុលពន្ធ**របស់ក្រុមហ៊ុន ដែលបានធ្វើការផ្គត់ផ្គង់សំភារៈ សេវា សំណង់ ជូនរដ្ឋ ហើយដែលក្រុមហ៊ុនទាំងនោះជំពាក់បំណុលពន្ធមិនទាន់ទូទាត់ ឱ្យបានជាប្រចាំជូននាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិសេសជូនរតនាគារជាតិនិងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ **ដើម្បីកាត់កង ទូទាត់ជាស្វ័យប្រវត្តិនូវបំណុលពន្ធទាំងនោះលើអាណត្តិដែលបានបោះផ្សាយ** ។ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋត្រូវគ្រប់គ្រងបំណុលពុំមែនសារពើពន្ធឱ្យបានជាប្រចាំព្រមទាំងផ្តល់របាយការណ៍បំណុលទាំងនេះជូននាយកដ្ឋានពាក់ព័ន្ធ ជាពិសេសជូនរតនាគារជាតិនិងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណដើម្បីជាមូលដ្ឋានទិន្នន័យសំរាប់វិធានការទូទាត់កាត់កងលើអាណត្តិបោះផ្សាយ ។ រតនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ នាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋត្រូវផ្ទៀងផ្ទាត់ជាមួយគ្នានូវចំនួនទឹកប្រាក់បំណុលទាំងនោះឱ្យបានត្រឹមត្រូវ ។

## ៦. <u>វិធីកិច្ចជំរះបញ្ជី និង ការទូទាត់</u>

- កិច្ចជំរះបញ្ជីគឺជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវពិតប្រាកដនៃចំណាយទាំងឡាយរបស់រដ្ឋ ។ ចំណាយថវិការដ្ឋត្រូវជំរះដោយអាណាប័ក ។ កិច្ចជំរះបញ្ជីនេះត្រូវធ្វើឡើងក្រោយចំណាយទាំងឡាយរបស់រដ្ឋត្រូវបាន សន្យា ព្រមជាមួយនិងការបញ្ជាក់ភាពត្រឹមត្រូវលើប្រាក់សក្ខីប័ត្រ ។ ដើម្បីសំរេចកិច្ចជំរះចំណាយនេះ អាណាប័ក ត្រូវបញ្ចេញ អាណត្តិបើក

ប្រាក់ ។ អាណត្តិបើកប្រាក់ ជាថ់ខាតត្រូវផ្លងទិដ្ឋាការពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។ គ្មានទិដ្ឋាការរបស់ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ អាណត្តិបើកប្រាក់នឹងគ្មានតំលៃទេចំពោះគណនេយ្យករបុខការនៃរតនាគារជាតិ ។

- **ការទូទាត់**គឺជាប្រព្រឹត្តកម្មដែលអាណាប័កត្រូវតែដោះបំណុលថវិការដ្ឋ រួមមាន **វដ្ឋទេយ្យបុរេប្រទាន** និង **ថវិកាបុរេប្រទាន** ។ វដ្ឋទេយ្យបុរេប្រទាន និងថវិកាបុរេប្រទាន **ត្រូវកត់ត្រាតាមដានការសម្យាចំណាយដូចធម្មតា** ទោះប្រាក់បុរេប្រទានជារូបិយប័ណ្ណអន្តរជាតិតាមរយៈប្ញលប្បទានប័ត្រក៏ដោយ ។ ធ្វើបែបនេះដើម្បីអាចមានឥណទាន ត្រៀមទុកទូទាត់ ។ វដ្ឋទេយ្យករ មិនត្រូវរង់រង់ តែត្រូវត្រះប្រមូលលិខិតយុត្តិការចំណាយដើម្បីរៀបចំជារបាយការណ៍ បូកសរុប យ៉ាងយូរបំផុតរយៈពេល ០១ ខែ ចាប់ពីកាលបរិច្ឆេទបានដកប្រាក់ពីរតនាគារជាតិ ព្រមទាំងរៀបចំអាណត្តិនិយ័តកម្មដើម្បីដាក់ជូនអាណាប័កពិនិត្យនិងចុះបាត្តលេខា ។ ភាពព្រងើយកន្តើយមិនប្រញាប់ប្រញាល់ប្រមូលលិខិតយុត្តិការនិងរៀបចំធ្វើរាយការណ៍និយ័តកម្មនិងធ្វើឱ្យ មានផលប៉ះពាល់ ជាយថាហេតុ :

  - មិនបានកត់ត្រានិងឆ្លុះបញ្ចាំងចំណាយថវិការដ្ឋ ។
  - កាត់បន្ថយការចំណាយឥណទាននៃឆ្នាំបន្ទាប់ ។

- កិច្ចជំរះបញ្ជីនិងការទូទាត់ចំណាយ បើក្នុងករណីអាណាប័កក្រសួង-ស្ថាប័នណាមួយ ឬមន្ទីរជំនាញខេត្ត-ក្រុងណាមួយនៅប្រកាន់ភាពព្រងើយកន្តើយនិងរឹងរូសមិនព្រមចាត់វិធានការឱ្យអង្គភាពជំនាញក្រោមឱវាទធ្វើការទូទាត់ជំរះបញ្ជីចំណាយបានទាន់ពេលវេលាក៏យ៉ាងហោចណាស់ក្នុងកាលបរិច្ឆេទនៃឆ្នាំថវិកាទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងចាត់បញ្ជាឱ្យធ្វើអធិការកិច្ចភ្លាម ហើយអាចនឹងឈានដល់ធ្វើសេចក្តីរាយការណ៍ជូនអាជ្ញាធរសវនកម្មជាតិ ដើម្បីចុះត្រួតពិនិត្យរកឱ្យឃើញពីការមិនគោរពវិន័យក្នុងកិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាជាតិ ក៏ដូចជាការមិនទទួលខុសត្រូវរបស់អ្នកដែលមានតួនាទីគ្រប់គ្រងប្រាក់កាសសាធារណៈដែរ ។

## ៧. វិធីការគ្រប់គ្រងថវិកា និង គណនេយ្យ របស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

ដោយផ្អែកតាមស្មារតីសារាចររបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលេខ ៩៦០៨ កបទ.សអ.ខម ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីចំណាយរបស់ស្ថានទូត និងរបាយការណ៍ប្រចាំខែ គ្រប់ស្ថានតំណាងនៃ ព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវពង្រឹងនិងបង្កើនប្រសិទ្ធភាពការកិច្ចសំខាន់ៗដូចតទៅ :

- ឯកឧត្តមរាជទូត ឧត្តមកុងស៊ុល ភារៈធារី ដែលជាប្រធានបេសកកម្មការទូត ហើយមានតួនាទីជាប្រធានស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។ នៅដើមត្រីមាសនីមួយៗ គ្រប់ស្ថានតំណាងនៅបរទេស ត្រូវបានផ្តល់តាមរយៈអាណត្តិបើកប្រាក់លើថវិកា របស់ក្រសួង ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នូវហរិញ្ញប្បទានរួមមួយស្មើនឹង មួយភាគបួន នៃឥណទានប្រចាំឆ្នាំ ។
- ប្រធានស្ថានតំណាងនៅបរទេស ត្រូវចាត់វិធីចំណាយ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ធ្វើការសម្រាំងជំរះបញ្ជីចំណាយ នៃស្ថានតំណាងរបស់ខ្លួន នៅក្នុងកំរិតនៃឥណទានដែលបានបែងចែកជូន និង ឬតាមវិធីដែលបានទទួល ។
- នៅស្ថានតំណាងកម្ពុជានីមួយៗ នៅបរទេស ត្រូវតែងតាំងគណនេយ្យ ដែលមានតួនាទីជាគណនេយ្យករ

ដោយឡែក ត្រូវបូកសរុបនូវរបាយការណ៍ចំណូល-ចំណាយដែលកើតមានឡើងក្នុងខែ ហើយផ្ញើមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមួយច្បាប់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ហ្វាក់ លេខ ៨៥៥ ២៣ ៤២៨ ២០០) មួយច្បាប់ឱ្យបានមុនថ្ងៃទី ០៥ នៃខែនីមួយៗ ។ ផ្អែកលើមូលដ្ឋាន ចំណូលដែលទទួលបាន ពីភ្នាក់ងារ គណនេយ្យតាមស្ថានតំណាងនីមួយៗ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណត្រូវកត់ត្រាបដិភាគនៃចំណូលនេះ លើទាយជ្ញទានដែល ត្រូវផ្តល់ជូនសាមីស្ថានតំណាង ដោយជូនដំណឹងជាលាយល័ក្ខអក្សរអំពីចំនួនកត់ត្រានេះ ។ នៅពេលទទួលបានសេចក្តីជូន ដំណឹងពីអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ភ្នាក់ងារគណនេយ្យត្រូវចុះលេខនា ដូចគ្នានឹងលេខនាដែលបានពណ៌នានេះ ។

- តាមរយៈតួនាទីជាគណនេយ្យករដោយឡែករបស់ស្ថានតំណាងនៅបរទេស ភ្នាក់ងារគណនេយ្យនីមួយៗ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( អគ្គាធិការដ្ឋាន ) និង ត្រូវបាននិទិត្ថ័យផងដែរពីអាជ្ញាធរសវនកម្មជាតិ ។

- ចាប់ពីត្រីមាសទីមួយ ឆ្នាំ ២០០៤ តទៅ តាមរយៈអាណត្តិបើកប្រាក់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹង ធ្វើការបង្វែរចំនួនទឹកប្រាក់ដែលត្រូវផ្តល់ ចូលគណនីចរន្ត របស់ស្ថានតំណាងទាំងនោះ ដែលបានបើកនៅធនាគារណាមួយនៅកន្លែងខ្លួន ដោយផ្អែកតាមរបាយការណ៍ចំណូលដែលកើតមានឡើងក្នុងខែរបស់គ្រប់ស្ថានតំណាងដែលបានផ្ញើមកក្រសួង ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ដូចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹង ធ្វើការបង្វែរសាច់ប្រាក់ជូនភ្នាក់ងារតែចំនួនទឹកប្រាក់ដែលនៅសល់ក្រោយពីបានដកចេញនូវចំនួនចំណូលជាក់ស្តែងដែលបានរាយការណ៍មក នោះ មានន័យថា អំណើះតទៅ ការបង់ចំណូលសាច់ប្រាក់របស់ស្ថានតំណាងនីមួយៗ នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស លែងត្រូវបានបញ្ជូនសាច់ប្រាក់មកធ្វើការបង់ជាក់ស្តែងនៅធនាគារជាតិក្នុងស្រុក ដូចមុនៗទៀតហើយ ។

ទទួលបានសារាចរនេះ សូមព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង និងប្រធានមន្ទីរជំនាញគ្រប់ខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់សហការគ្នា អនុវត្តឱ្យបានហ្មត់ចត់និងមានប្រសិទ្ធភាពខ្ពស់បំផុត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន ៖
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់ខេត្ត-ក្រុង
-គ្រប់មន្ទីរជំនាញខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ  សាសនា  ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

# ប្រ កា ស
## ស្តីពី
## ការទូទាត់ភាគលាភជាមុន

### ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## ស ំ រេ ច

**ប្រការ ១ .-**

ធនាគារពាណិជ្ជនិងធនាគារឯកទេសត្រូវបានអនុញ្ញាតឱ្យទូទាត់ភាគលាភបាន លុះត្រាតែ ប្រាក់ចំណេញត្រូវបានទទួលស្គាល់ជាក់លាក់ ។

**ប្រការ ២ .-**

ប្រាក់ចំណេញប្រចាំឆ្នាំត្រូវបានទទួលស្គាល់ជាក់លាក់នៅពេលដែលសវនករគណនីឯករាជ្យបានអនុម័តបញ្ជីគណនេយ្យប្រចាំឆ្នាំ ។

ធនាគារមិនអាចទូទាត់ភាគលាភនៅមុនពេលអនុមតិនេះទេ ។

**ប្រការ ៣ .-**

ប្រសិនបើភាគលាភត្រូវបានទូទាត់ជាមុន ធនាគារជាតិនៃកម្ពុជាអាចបង្ខំឱ្យភាគទុនិកសងភាគលាភដែលបានទូទាត់ជាមុនមកវិញយ៉ាងឆាប់ដោយបូកបន្ថែមជាមួយការប្រាក់ដែលបានគណនាដូច ឥណទានលើសសមតុល្យចំពោះឯកត្តជន ។

**ប្រការ ៤ .-**

ថ្វីបើមានប្រការ ៣ ក៏ដោយ ការខកខានមិនបានគោរពតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មស្របតាមមាត្រា ៥២នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៥ .-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៦ .-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៤

**ទេសាភិបាល**

ជា ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number [illegible]

# PRAKAS

## on

## PAYMENTS OF DIVIDENDS IN ADVANCE

-----------------------

## The Governor of The National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the Law on the organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18,1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia;
- Pursuant to the request of the General Director of the National Bank of Cambodia.

## Decides

**Article 1.**

Commercial and specialized banks are only allowed to pay dividends if the annual profit is absolutely certain.

**Article 2.**

Annual profit is absolutely certain, once annual accounts have been approved by external auditors. Banks cannot pay dividends before this approval.

**Article 3.**

If dividends are paid in advance, National Bank of Cambodia can compel the shareholders to immediately repay the dividends paid in advance, plus an interest calculated as for an overdraft to individuals.

**Article 4.**

Notwithstanding article 3, any failure to abide by the present regulation will be sanctioned according to article 52 of the Law on the Banking and Financial Institutions.

**Article 5.**

The General Direction, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under of the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 6.**

This Prakas shall have effect from the signing date.

Phnom Penh, January 14, 2004

**The Governor**
Signed and sealed: **CHEA CHANTO**

cc: - The member of the Board of Directors
- The parties concerned as stated in Article 5
- File
- CM "for info"
- Administration
- Department of CM
"for publication in the National Gazette"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ: ០០៧ ប្រក.កសក.បុ

**ប្រកាស**

ស្តីពីការតែងតាំងមន្ត្រីរាជការ

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៦ នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញ ព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៨០២ / ០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញ អនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យ លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះ នាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញលិខិតលេខ លេខ ៥០៥ បស.គត ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៣ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីការឯកភាពជាគោលការណ៍តែងតាំងមន្ត្រីរដ្ឋបាលព្រៃឈើ

**ស ម្រេ ច**

**ប្រការ ១** : ត្រូវបានតែងតាំងមន្ត្រីរដ្ឋបាលព្រៃឈើ ជានាយ នាយរង នៃខណ្ឌរដ្ឋបាលព្រៃឈើ ដូចមានរាយនាមខាងក្រោម:

១-<u>ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម</u> :

| | | | |
|---|---|---|---|
| ១-លោក | សួន | ប៊ុនថន | ជានាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម |
| ២-លោក | ហេង | ប៊ិនយិ | ជានាយរង |

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B.V.D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

| | | | |
|---|---|---|---|
| ៣-លោក | ប្រាក់ | ណូម៉ា | ជានាយរងខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម |
| ៥-លោក | អ៊ុង | យ៉ិត | ជានាយរង |
| ៦-លោក | ឃឹម | អូន | ជានាយរង |

២-ខណ្ឌរដ្ឋបាលព្រៃឈើក្រចេះ :

| | | | |
|---|---|---|---|
| ១-លោក | ឈៀង | តុលា | ជានាយខណ្ឌរដ្ឋបាលព្រៃឈើក្រចេះ |
| ២-លោក | ផ្លោក | ថៃ | ជានាយរង |
| ៣-លោក | សួយ | សារិទ្ធ | ជានាយរង |
| ៤-លោក | ទេព | សាម៉ៃ | ជានាយរង |
| ៥-លោក | គល់ | សុវណ្ណ | ជានាយរង |

៣-ខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង :

| | | | |
|---|---|---|---|
| ១-លោក | ឌិម | ម៉ាក់ធារី | ជានាយខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង |
| ២-លោក | ឌី | សុខុម | ជានាយរង |
| ៣-លោក | ទូន | ពៅរតនា | ជានាយរង |
| ៤-លោក | ជាម | យូដុង | ជានាយរង |

៤-ខណ្ឌរដ្ឋបាលព្រៃឈើរតនគិរី :

| | | | |
|---|---|---|---|
| ១-លោក | យន | សារ៉េត | ជានាយខណ្ឌរដ្ឋបាលព្រៃឈើរតនគិរី |
| ២-លោក | ហុង | ភា | ជានាយរង |
| ៣-លោក | យូ | កាណវិមាន | ជានាយរង |
| ៤-លោក | លឹម | ម៉ៅ | ជានាយរង |

៥-ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី :

| | | | |
|---|---|---|---|
| ១-លោក | ហ៊ី | សុផល | ជានាយខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី |
| ២-លោក | ប៊ូ | សុវុធ | ជានាយរង |
| ៣-លោក | ឡាយ | ចាន់ | ជានាយរង |
| ៤-លោក | ទីប | សុវណ្ណរិទ្ធិ | ជានាយរង |

៦-ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ :

| | | | |
|---|---|---|---|
| ១-លោក | គង់ | ណារិន | ជានាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ |
| ២-លោក | ស៊ូ | សោគន្ធ | ជានាយរង |
| ៣-លោក | ស៊ីម | ឡាប៉ុង | ជានាយរង |
| ៤-លោក | តិប | ញាតា | ជានាយរង |

៧-ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ :

| | | | |
|---|---|---|---|
| ១-លោក | ហ៊ីម | វិសាល | ជានាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ ទទួលបន្ទុកស្តីទី |
| ២-លោក | ជៀង | រិទ្ធិ | ជានាយរង |

៨៧

| | | | |
|---|---|---|---|
| ៣-លោក | គង់ | ពុទ្ធារ៉ា | ជានាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ |
| ៤-លោក | សៀង | រស់ | ជានាយរង |
| ៥-លោក | ផាន់ | ភីន | ជានាយរង |

៨-ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប :

| | | | |
|---|---|---|---|
| ១-លោក | លី | ជូបៀង | ជានាយខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប |
| ២-លោក | ទា | គឹមសុទ្ធ | ជានាយរង |
| ៣-លោក | ប្រាក់ | ម៉ារីណា | ជានាយរង |
| ៤-លោក | ទូច | សាលីន | ជានាយរង |

៩-ខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង :

| | | | |
|---|---|---|---|
| ១-លោក | ទុង | ធីរមៀ | ជានាយខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង |
| ២-លោក | ជិត | ដៃណុង | ជានាយរង |
| ៣-លោក | តូច | មុនី | ជានាយរង |
| ៤-លោក | ប្រាជ្ញ | ពេជ្រភិរុណ | ជានាយរង |

១០-ខណ្ឌរដ្ឋបាលព្រៃឈើពោធិសាត់ :

| | | | |
|---|---|---|---|
| ១-លោក | ពិន | ផាន់នី | ជានាយខណ្ឌរដ្ឋបាលព្រៃឈើពោធិសាត់ |
| ២-លោក | ម៉ម | អៀង | ជានាយរង |
| ៣-លោក | គីម | ចន្ថា | ជានាយរង |
| ៤-លោក | ប៊ិច | កេត | ជានាយរង |

១១-ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ឆ្នាំង :

| | | | |
|---|---|---|---|
| ១-លោក | ស៊ិន | កុសល | ជានាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ឆ្នាំង |
| ២-លោក | នូវ | ប៉ៅលីន | ជានាយរង |
| ៣-លោក | ផា | ប៊ុនថា | ជានាយរង |

១២-ខណ្ឌរដ្ឋបាលព្រៃឈើកណ្ដាល :

| | | | |
|---|---|---|---|
| ១-លោក | ហ៊ុន | អៀង | ជានាយរងខណ្ឌរដ្ឋបាលព្រៃឈើកណ្ដាល ទទួលបន្ទុករួម |
| ២-លោក | ប៉ូ | ប៊ុនឡេង | ជានាយរង |
| ៣-លោកស្រី | លី | សាគីណោ | ជានាយរង |

១៣-ខណ្ឌរដ្ឋបាលព្រៃឈើកំពត :

| | | | |
|---|---|---|---|
| ១-លោក | ម៉ាក់ | ហ៊ាង | ជានាយខណ្ឌរដ្ឋបាលព្រៃឈើកំពត |
| ២-លោក | ពត | ផាណាល់ | ជានាយរង |
| ៣-លោក | សួន | ស៊ុម | ជានាយរង |

១៤-ខណ្ឌរដ្ឋបាលព្រៃឈើក្រុងព្រះសីហនុ :

| | | | |
|---|---|---|---|
| ១-លោក | សូត្រ | អុន | ជានាយខណ្ឌរដ្ឋបាលព្រៃឈើក្រុងព្រះសីហនុ |

ស៊ា/

២-លោក ឌួង សុជាតិ ជានាយរងខណ្ឌរដ្ឋបាលព្រៃឈើក្រុងព្រះសីហនុ

៣-លោក វង្ស ច័ន្ទតារា ជានាយរង

១៥-<u>ខណ្ឌរដ្ឋបាលព្រៃឈើកោះកុង</u> :

១-លោក ស៊ុម សេរីវុទ្ធ ជានាយខណ្ឌរដ្ឋបាលព្រៃឈើកោះកុង

២-លោក មាស ស៊ីថា ជានាយរង

៣-លោក សុង ឃាង ជានាយរង

៤-លោក ឃុន សុផល ជានាយរង

៥-លោក ឆៃ សារ៉ាន់ ជានាយរង

**ប្រការ ២ :** ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធានរដ្ឋបាលព្រៃឈើ នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីជន ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០០៤

រដ្ឋមន្ត្រី

ច័ន្ទ សារុន

<u>**កន្លែងទទួល**</u>

- ទីស្តីការ គណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង " <u>ដើម្បីជូនជ្រាប</u> "
- ដូចបានក្នុងប្រការ ៣ " <u>ដើម្បីអនុវត្ត</u> "
- ឯកសារ - កាលប្បវត្តិ